33

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ១៧០៧ អយក

ប្រកាស
ស្តីពីកំរិតសមមូលសញ្ញាបំត្រ

02-12-05
3044

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស-រកម-០៧០៤-០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយ ប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញប្រកាសលេខ ២៥៧ អយកក្រប ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០២ ស្តីពីការបើកវិទ្យាល័យកំពង់ឈើទាល ស្រុកប្រាសាទសំបូរ ។

-បានឃើញសារាចរ លេខ ០០១ អយក សរ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីគំរូរចនាសម្ព័ន្ធ និងឈ្មោះសញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈ ។

## សម្រេច

**ប្រការ ១** : សញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈកំរិត III មានតំលៃស្មើនឹងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ និងបំពេញវិជ្ជា ។

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh

**ប្រការ ២** : សិស្សដែលមានសញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈកំរិត III អាចដាក់ពាក្យចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដោយគោរពតាមលក្ខខណ្ឌដោយឡែករបស់សាមីគ្រឹះស្ថានឧត្តមសិក្សានោះ ។

**ប្រការ ៣** : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានអប់រំ ប្រធាននាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា ។

ភ្នំពេញ,ថ្ងៃទី ... ឆ្នាំ២០០៥

បណ្ឌិត កុល ផេង

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួង

  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៣
- កាលប្បវត្តិ
- ឯកសារ